International Labour Organization | BetterWork | ILR School

ILO brief

# គម្រោងការងារសមរម្យក្នុងសង្វាក់ផ្គត់ផ្គង់សំលៀកបំពាក់ក្នុងតំបន់អាស៊ី

ខែ មីនា ឆ្នាំ២០២១

## ការកាត់បន្ថយផលប៉ះពាល់ដែលបន្សល់ទុក (footprint)? របៀបវាយតម្លៃការបំភាយកាបូនក្នុងវិស័យកាត់ដេរនៅតំបន់អាស៊ី

របាយការណ៍នេះពិនិត្យមើលការបំភាយកាបូនក្នុងវិស័យកាត់ដេរ ដោយប្រើប្រាស់វិធីសាស្ត្រ ២ សម្រាប់គណនាការបំភាយ ៖ ការវាយតម្លៃវដ្តជីវិត (LCA) និងការកំណត់បរិមាណនៃការបំភាយកាបូន (carbon accounting) ដែលអនុលោមតាមពិធីសារស្តីពីឧស្ម័នផ្ទះកញ្ចក់។ របាយការណ៍នេះមានគោលបំណងផ្តល់ចំណេះដឹងស្តីពីមូលហេតុ និងផ្នែកដែលមានការប្រែប្រួលអាំងតង់ស៊ីតេកាបូនក្នុងវិស័យវាយនភណ្ឌ និងកាត់ដេរ ក្នុងសង្វាក់ផ្គត់ផ្គង់ និងផ្នែកដែលគួរផ្តោតអាទិភាពលើសកម្មភាពកាត់បន្ថយកាបូនក្នុងវិស័យនេះ។

## សេចក្តីសង្ខេប


វិស័យវាយនភណ្ឌ និងកាត់ដេរ ជាវិស័យដែលរួមចំណែកយ៉ាងច្រើនដល់ការបំភាយកាបូនក្នុងសកលលោក ប្រមាណ ៦-៨ ភាគរយនៃបរិមាណកាបូនសរុបដែលបានបំភាយក្នុងបរិយាកាស ឬស្មើនឹង ១,៧ ពាន់លានតោន/ឆ្នាំ។ កិច្ចព្រមព្រៀងទីក្រុងប៉ារីស កំណត់ពីការកម្រិតនៃការឡើងកម្តៅផែនដីក្រោម ២ អង្សារ ធៀបនឹងកម្រិតមុនសម័យឧស្សាហកម្ម (ត្រឹម ១,៥ អង្សារ)។ ការកាត់បន្ថយការបំភាយឧស្ម័នដែលពាក់ព័ន្ធនឹងការសម្រេចបានគោលដៅនេះ មានទំហំធំធេងណាស់។ ពោលគឺដើម្បីសម្រេចចំណុចដៅនេះ គេត្រូវកាត់បន្ថយការបំភាយឧស្ម័នទូទាំងពិភពលោកឱ្យបាន ៤៥ ភាគរយ (កម្រិតឆ្នាំ ២០១០) ត្រឹមឆ្នាំ ២០៣០ និងកាត់បន្ថយឱ្យដល់ ០ ត្រឹមឆ្នាំ ២០៥០។ ភាគីពាក់ព័ន្ធក្នុងវិស័យកាត់ដេរ បានចូលរួមកិច្ចប្រជុំនៅឆ្នាំ ២០១៨ ដើម្បីប្តេជ្ញាអនុវត្តសកម្មភាពអាកាសធាតុតាមរយៈអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) ធម្មនុញ្ញឧស្សាហកម្មថ្មៃម៉ូដសម្រាប់សកម្មភាពអាកាសធាតុ។ ប្រទេសហត្ថលេខីនៃធម្មនុញ្ញនេះបានប្តេជ្ញាកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ឱ្យបាន ៣០ ភាគរយត្រឹមឆ្នាំ ២០៣០ (ពីកម្រិតគោលនៅឆ្នាំ ២០១៥) និង ១០០ ភាគរយត្រឹមឆ្នាំ ២០៥០។ នេះជាបញ្ហាប្រឈមដ៏ធំមួយ ព្រោះការសម្រេចបានគោលដៅនៃការកាត់បន្ថយការបំភាយឧស្ម័នឱ្យបាន ៣០ ភាគរយក្នុងវិស័យនេះ ទាមទារការកាត់បន្ថយបរិមាណកាបូនឌីអុកស៊ីតឱ្យបានជាង ០,៥ ពាន់លានតោនក្នុងមួយឆ្នាំ ត្រឹមឆ្នាំ ២០៣០។ ដើម្បីដោះស្រាយបញ្ហានេះ ទាមទារការកែប្រែនៅកម្រិតប្រព័ន្ធក្នុងផលិតកម្ម និងការប្រើប្រាស់វាយនភណ្ឌ និងសំលៀកបំពាក់ ហើយអាចនឹងបង្កផលប៉ះពាល់យ៉ាងខ្លាំងលើរបៀប និងផ្នែកដែលសំលៀកបំពាក់ត្រូវបានផលិត និងការងារដែលពាក់ព័ន្ធនឹងផលិតកម្មនេះ។ របាយការណ៍នេះផ្តល់ការពន្យល់ពីរបៀប និងផ្នែកដែលការបំភាយកាបូនកើនឡើងក្នុងសង្វាក់ផ្គត់ផ្គង់នៃវិស័យវាយនភណ្ឌ និងកាត់ដេរ សម្រាប់ជា precursor ក្នុងការកំណត់រកផ្នែកដែលគួរតែជាអាទិភាពនៃការផ្តោតសកម្មភាពក្នុងសង្វាក់ផ្គត់ផ្គង់។ លទ្ធផលរកឃើញបង្ហាញថា ការបំភាយឧស្ម័នកើតឡើងក្នុងសង្វាក់តម្លៃទាំងមូល ប៉ុន្តែមានច្រើនបំផុតក្នុងដំណាក់កាលផលិតអំបោះឆៅ និងក្រណាត់ ដែលស៊ីសង្វាក់គ្នានឹងផលប៉ះពាល់បរិស្ថានផ្សេងទៀត ដូចជា ការប្រើប្រាស់ទឹក និងសារធាតុគីមី។ ការប្រើប្រាស់ថាមពលជាកត្តារួមចំណែកដ៏សំខាន់ដល់ការបំភាយ

ឧស្ម័នផ្ទះកញ្ចក់ក្នុងវិស័យវាយនភណ្ឌ និងកាត់ដេរ។ តម្រូវការថាមពលយ៉ាងច្រើននៅគឺដំណាក់កាលកែច្នៃផលិតផលសើម (ការជ្រលក់ពណ៌ និងការតុបតែងចុងក្រោយ) ដែលថាមពលត្រូវបានប្រើប្រាស់ដើម្បីកម្តៅទឹក និងសម្ងួតក្រណាត់។ អាំងតង់ស៊ីតេកាបូននៃប្រភពថាមពលដែលត្រូវបានប្រើប្រាស់ក្នុងមជ្ឈមណ្ឌលផលិតកម្ម (ធ្យូងថ្ម ឬឧស្ម័នធម្មជាតិ) បង្កជាអាំងតង់ស៊ីតេខ្ពស់នៃការបំភាយឧស្ម័នសម្រាប់ផលិតកម្មវាយនភណ្ឌ។ ក្រៅពីនេះ ការប្រើប្រាស់ថាមពលត្រូវចំណាយថ្លៃដើមយ៉ាងច្រើនក្នុងផ្នែកដែលប្រើប្រាស់ថាមពលច្រើនក្នុងសង្វាក់តម្លៃ ដូចជា រោងចក្រវាយនភណ្ឌ និងរោងចក្រកាត់ដេរ។ ដូច្នេះ មានទាំងចលករសេដ្ឋកិច្ច និងចលករបរិស្ថានសម្រាប់ការកាត់បន្ថយការបំភាយឧស្ម័នក្នុងវិស័យនេះ។ របាយការណ៍នេះពិនិត្យមើលការបំភាយកាបូនក្នុងវិស័យកាត់ដេរ ដោយប្រើវិធីសាស្ត្រសំខាន់ៗ ២ សម្រាប់គណនាការបំភាយ ដើម្បីផ្តល់ចំណេះដឹងស្តីពីមូលហេតុ និងផ្នែកដែលមានការប្រែប្រួលអាំងតង់ស៊ីតេកាបូនក្នុងវិស័យវាយនភណ្ឌ និងកាត់ដេរ ក្នុងសង្វាក់ផ្គត់ផ្គង់ និងផ្នែកដែលគួរផ្តោតអាទិភាពលើសកម្មភាពកាត់បន្ថយកាបូនក្នុងវិស័យនេះ។ វិធីសាស្ត្រស្តង់ដារ ២ សម្រាប់វាស់វែងការបំភាយឧស្ម័នផ្ទះកញ្ចក់រួមមានការវាយតម្លៃវដ្តជីវិត (LCA) និងការកំណត់បរិមាណនៃការបំភាយកាបូន (carbon accounting) ដែលអនុលោមតាមពិធីសារស្តីពីឧស្ម័នផ្ទះកញ្ចក់។

របាយការណ៍នេះគូសបញ្ជាក់ពីផលវិបាកនៃការបំភាយកាបូនក្នុង ៖

- ការប្រើប្រាស់ក្រណាត់ និងវាយនភណ្ឌផ្សេងៗ (វត្ថុធាតុធម្មជាតិ ទល់នឹងវត្ថុធាតុផលិតដោយមនុស្ស)
- អាំងតង់ស៊ីតេកាបូននៃប្រភពថាមពលក្នុងមជ្ឈមណ្ឌលផលិតកម្ម
- ទំហំផលិតកម្មទាំងមូល និង
- រយៈពេល និងអាំងតង់ស៊ីតេនៃដំណាក់កាលប្រើប្រាស់ (ដូចជា ឥរិយាបថរបស់អ្នកប្រើប្រាស់ក្នុងការលាងជម្រះ និងស្លៀកពាក់)។

វិមាត្រ និងល្បឿននៃការផ្លាស់ប្តូរទូទាំងប្រព័ន្ធក្នុងការផលិតសំលៀកបំពាក់ដែលចាំបាច់ ដើម្បីសម្រេចចំណុចដៅសម្រាប់សកម្មភាពអាកាសធាតុ មានន័យថានឹងមានផលប៉ះពាល់យ៉ាងខ្លាំងលើពិភពការងារក្នុងសមាសភាគទាំងនេះនៃសង្វាក់ផ្គត់ផ្គង់។ ការកាត់បន្ថយការបំភាយកាបូន នឹងតម្រូវឱ្យមានការផ្លាស់ប្តូរគំរូអាជីវកម្ម បូករួមនឹងនវានុវត្តន៍បច្ចេកវិទ្យា និងដំណើរការ។ ក្នុងការសម្រេចបាននូវការផ្លាស់ប្តូរទាំងនេះ ចាំបាច់ត្រូវមានការវិនិយោគផ្នែកមូលធនមនុស្ស និងហិរញ្ញវត្ថុក្នុងរយៈពេលថេរមួយ ដើម្បីធានាអន្តរកាលប្រកបដោយយុត្តិធម៌។

**ព័ត៌មានទំនាក់ទំនង**

**ការិយាល័យ ILO ប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិច**
United Nations Building
Rajdamnern Nok Avenue
Bangkok 10200, Thailand

T: +66 2288 1234
F: +66 2280 1735
E: BANGKOK@ilo.org
W: www.ilo.org/asiapacific

©អង្គការអន្តរជាតិខាងការងារ ឆ្នាំ ២០២១